# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១០៥....អនក្រ.បក

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០១

# អនុក្រឹត្យ

## ស្តីពីការបង្កើតវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ
## របស់ក្រសួងអប់រំ យុវជននិងកីឡា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជននិងកីឡា

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩១ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងពាណិជ្ជកម្ម

-តាមសំណើរបស់ក្រសួងអប់រំ យុវជននិងកីឡា

## សម្រេច

**មាត្រា១:** ប្រែក្លាយ និង តំឡើងឋានៈ សាលាមធ្យមសិក្សាឯកទេសពាណិជ្ជកម្ម ទៅជាវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ National Institute of Business "វ.ជ.ព" ។

វិទ្យាស្ថាននេះត្រូវស្ថិតនៅក្រោមឱវាទ ក្រសួងអប់រំ យុវជននិងកីឡា ។

**មាត្រា២:** វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រមានភារៈកិច្ច :

-អប់រំបណ្តុះបណ្តាលធនធានមនុស្សតាំងពីកំរិតមធ្យមសិក្សាឯកទេស និង បរិញ្ញាប័ត្រ ដើម្បីឆ្លើយតបទៅនឹងតំរូវការរីកចំរើននៃសេដ្ឋកិច្ចទីផ្សារសេរី និង គោលនយោបាយអាទិភាព សំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣:** វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រមានឋានៈស្មើថ្នាក់នាយកដ្ឋាន ។

**មាត្រា៤:** នាយកវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ មានបុព្វសិទ្ធិស្មើនឹងប្រធាននាយកដ្ឋាន និង មាននាយករងមួយរូប ឬ ច្រើនរូប ជាជំនួយការចាំបាច់ ។

**មាត្រា៥:** ចំពោះមុខនេះវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រមាន:

-ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

-ការិយាល័យសិក្សា

-ការិយាល័យទំនាក់ទំនងស្ថាប័ន-រោងចក្រ-សហគ្រាស

-ដេប៉ាតឺម៉ង់គណនេយ្យ

-ដេប៉ាតឺម៉ង់គ្រប់គ្រង

-ដេប៉ាតឺម៉ង់ម៉ាឃីតធីង

ទៅអនាគតវិទ្យាស្ថានជាតិនឹងអាចបើកការិយាល័យ និង ដេប៉ាតឺម៉ង់មួយចំនួនទៀតតាមសំណូមពរភារៈកិច្ចជាក់ស្តែង ។

**មាត្រា៦:** វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ កាន់កាប់ និងប្រើប្រាស់គណនេយ្យតាមប្រព័ន្ធគណនេយ្យសាធារណៈដែលត្រូវបានឧបត្ថម្ភពីថវិកាជាតិសំរាប់បណ្តុះបណ្តាល និងមានខ្ទង់គណនេយ្យដោយឡែក

**មាត្រា៧:** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធ និង វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហ៊ុន សែន

ចម្លងជូន

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៨ " ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ